

# NHEM EN

## A KHMER ROUGE PHOTOGRAPHER

# FORGIVENESS & RECONCILIATION

**A Project of the Documentation Center of Cambodia**
**January 22, 2007**

ញ៉ែម អេន អ្នកថតរូបខ្មែរក្រហម សុំខមាទោសនិងផ្សះផ្សាជាតិ

# គោលបំណងនៃការបង្កើតសារមន្ទីរ

- ដើម្បីសុំខមាទោស
- ដើម្បីផ្សះផ្សា រខាង
    - ញ៉ៀម អេន និងសាច់ញាតិរបស់គាត់
    - ញ៉ៀម អេន និងជនរងគ្រោះដែលបានជាប់ឃុំឃាំងនៅមន្ទីរស-២១
    - ជនរងគ្រោះនិងជនដែដល់នៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម

# សកម្មភាពធ្វើឡើងដើម្បីសម្រេចឱ្យបាននូវគោលបំណង

- ពិពណ៌រូបថត
- បើកការពិភាក្សាទូលាយ
- រៀបចំដំណើរទស្សនកិច្ចទៅតំបន់អន្លង់វែង

# ការចូលរួមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

- ថែរក្សាឯកសារប្រវត្តិសាស្ត្រ
  - ជួសជុលឡើងវិញ, ថតចម្លង, បញ្ចូលទិន្នន័យ
- បោះពុម្ពផ្សាយ
- រៀបចំធ្វើពិពណ៌
  - ផ្តល់ជំនួយជាលក្ខណៈបច្ចេកទេស និងរចនាពិពណ៌

# សារមន្ទីរនិងជួយលើកកម្ពស់

- ការថែរក្សាប្រវត្តិសាស្ត្រ
- ការបង្រួបបង្រួមសង្គមជាតិ
  - បង្កើតនូវការយល់គ្នាទៅវិញទៅមក
- ការអប់រំ
  - ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
  - ការទទួលខុសត្រូវ  និងសុំខមាទោស
  - ការអធ្យាស្រ័យ  និងការអត់ឱនដល់គ្នាទៅវិញទៅមក

# ញ៉ែម អេន អំឡុងពេលការសុំខមាទោសជាសាធារណៈ



អ្នកកាសែតជាតិនិងអន្តរជាតិកំពុងថតរូប ញ៉ែម អេន នៅឯសន្និសីទកាសែត
ដែលរៀបចំឡើងនៅស្ថានទូតអាមេរិក ភ្នំពេញ

# ញ៉ែម អេន អំឡុងពេលការសុំខមាទោសជាសាធារណៈ




ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ ម៉ូសូម៉េលី ចាប់ដៃជាមួយ

ញ៉ែម អេន ដែលជាអតីតអ្នកថតរូបរបស់ខ្មែរក្រហម

# ញ៉ែម អេន អំឡុងពេលការសុំខមាទោសជាសាធារណៈ




ពីឆ្វេងទៅស្តាំៈ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, ឯកអគ្គរដ្ឋទូតអាមេរិក, ញ៉ែម អេន,
ប៉ែន សមិទ្ធិ និពន្ធនាយកកាសែតរស្មីកម្ពុជា និង ទីប្រឹក្សារបស់ ញ៉ែម អេន

# សុន្ទរកថារបស់ឯកអគ្គរដ្ឋទូត ចូសេហ្វ មូស្សូមេលី និងអ្នកថតរូបខ្មែរក្រហមឈ្មោះ ញ៉ែម អេន

អរុណសួស្តី! ខ្ញុំមានសេចក្តីរីករាយសូមស្វាគមន៍អស់លោក លោកស្រីទាំងអស់ដែលបានមកកាន់ស្ថានទូតអាមេរិកនៅថ្ងៃនេះ ដើម្បីជួបជាមួយលោក ញ៉ែម អេន ដែលជាអ្នកថតរូបនៃរបបខ្មែរក្រហម ដែលបានថតរូបជាច្រើនសន្លឹកនៅក្នុងបន្ទប់គុកទួលស្លែង។ រូបថតទាំងនោះត្រូវបានដាក់បង្ហាញពេញនៅក្នុងបន្ទប់ធំនៃអតីតគុកទួលស្លែង។ រូបថតទាំងនោះធ្វើឱ្យអ្នកទស្សនាគ្រប់គ្នាមានការរន្ធត់ចិត្តជាខ្លាំង។ ភ្នែករបស់ជនរងគ្រោះម្នាក់ៗ សម្លឹងមករកយើង លងយើង ស្រែកមកកាន់យើង បន្ទាប់ពីរូបថតទាំងនេះស្ថិតក្នុងភាពស្ងប់ស្ងាត់អស់រយៈពេលបីទសវត្សរ៍មកហើយនោះ។ ពុំមាននរណាម្នាក់ដែលបានទៅទស្សនាគុកទួលស្លែងអាចបំភ្លេចរូបថតទាំងនោះទេ។

ទោះបីជាមានការចោទប្រកាន់និងការនិយាយបញ្ឆិតបញ្ឆៀង អំពីអ្នកដែលបានថតរូបទាំងនេះយ៉ាងណាក្តី ក៏រូបថតទាំងនេះគឺជាតឹកតាងដែលមិនអាចប្រកែកបាននៃភាពយង់ឃ្នងរបស់របបខ្មែរក្រហមបានដែរ។ យើងទាំងអស់គ្នាបានដឹងហើយតាមរយៈការសិក្សាអង្កេតនៅពេលថ្មីៗនេះថា មានប្រជាជនខ្មែរវ័យក្មេងជាច្រើនមិនជឿថា មានអំពើប្រល័យពូជសាសន៍បានកើតឡើង និងជឿថាឪពុកម្តាយរបស់ពួកគេពិតជាបាននិយាយបំភ្លើសនូវអំពើដែលគួរឱ្យរន្ធត់នោះ ដូចនេះមានតែរូបថតទាំងនេះទេដែលជួយរំឭកដល់មនុស្សគ្រប់ៗគ្នាអំពីទំហំធំធេងពិតប្រាកដនៃឧក្រិដ្ឋកម្មនោះ។ យើងស្ទើរតែគ្មានអារម្មណ៍ចម្លែកចំពោះអំពើឃោរឃៅដែលកើតមានរាល់ថ្ងៃ ដែលយើងអាននៅលើទំព័រកាសែតរបស់យើងរាល់ព្រឹក ប៉ុន្តែខ្ញុំគិតថា យើងមានអារម្មណ៍ចម្លែកចំពោះរូបថតទាំងនោះ ពីព្រោះរូបថតទាំងនេះតែងតែធ្វើឱ្យយើងមានអារម្មណ៍មិនស្ងប់និងមិនស្រួលក្នុងចិត្តជានិច្ច។ យើងតែងតែឮពាក្យដែលគេច្រើននិយាយថា រូបថតមួយមានតម្លៃស្មើនឹងមួយពាន់ពាក្យ។ រូបនីមួយៗមានតម្លៃស្មើនឹងទឹកភ្នែកមួយពាន់តំណក់។

ទន្ទឹមនឹងការរួមចំណែកមួយយ៉ាងសំខាន់នៃរូបថតទាំងនេះ ក្នុងការថែរក្សានិងចងក្រងទុកជាឯកសារស្តីពីអំពើឃោរឃៅនៃរបបខ្មែរក្រហម ខ្ញុំគិតថា លោក ញ៉ែម អេន ជាឧទាហរណ៍គំរូដ៏ល្អមួយ ដោយលោកបានសុំខមាទោសចំពោះការមានចំណែករបស់លោកនៅក្នុងអំពើឃោរឃៅនោះ។ បើប្រៀបធៀបទៅនឹងអ្វីដែលលោកបាននឹងកំពុងធ្វើនៅពេលនេះ គឺផ្ទុយពីអ្វីដែលពុំមានមេដឹកនាំខ្មែរក្រហមណាម្នាក់បានចេញមុខសារភាពកំហុស ឬ ទទួលយកការស្តីបន្ទោសចំពោះឧក្រិដ្ឋកម្មដ៏ឃោរឃៅនៃរបបនោះ។ ដើម្បីឱ្យមានការផ្សះផ្សាជាតិពិតប្រាកដនៅកម្ពុជា អ្នកដែលបានជួយប្រព្រឹត្តអំពើឃោរឃៅទាំងនេះ ត្រូវហ៊ានចេញមុខទទួលស្គាល់អំពើឧក្រិដ្ឋរបស់ខ្លួន។

ពិតមែនហើយថា ការបើកសារមន្ទីរនេះនឹងមិនធានាដល់ការផ្សះផ្សាជាតិ ឬសងជំងឺចិត្តចំពោះការឈឺចាប់របស់ជនរងគ្រោះនោះទេ។ នេះគ្រាន់តែជាជំហានតូចដ៏មានសារសំខាន់មួយប៉ុណ្ណោះ។

យើងមានមោទកភាពផងដែរនៅថ្ងៃនេះ យើងមានមិត្ត និង សហការីរបស់យើងមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ជាពិសេស លោក ឆាំង យុ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកសហការយ៉ាងជិតស្និទជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា និងជួយផ្តល់ថវិកាដល់សកម្មភាពរបស់មជ្ឈមណ្ឌលនេះអស់រយៈពេលមួយទសវត្សរ៍មកហើយ។ យើងមានមោទកភាពចំពោះការខិតខំប្រឹងប្រែងរួមគ្នារបស់យើងក្នុងការរក្សាទុកប្រវត្តិអតីតកាល និងនាំជនមានទោសមកកាត់ទោស។

# សេចក្តីអនុញ្ញាតិពីរាជរដ្ឋាភិបាលកម្ពុជា



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមករា ឆ្នាំ ២០០៧

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ជម្រាបមក

លោក ញ៉ែម គេន អភិបាលរង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

យោង : -លិខិតស្នើសុំ ចុះថ្ងៃទី២៨.១២.២០០៦ របស់លោក ញ៉ែម គេន អភិបាលរងស្រុកអន្លង់វែង ។

ហ៊ឹម ឆែម

# ផែនការ និងថវិកាចំណាយ




ការអង្គាសថវិកា:

- ក្រុមហ៊ុនឯកជន
- រដ្ឋាភិបាលជាតិ និងអន្តរជាតិ
- អ្នកស្រុក អ្នកភូមិនៅអន្លង់វែង

# សូមអរគុណ!

បើមានពត៌មានបន្ថែម  សូមទំនាក់ទំនងៈ

ញ៉ែម  អេន

ទូរស័ព្ទលេខៈ  ០១២  ៦២៨  ១២៩